# សាកលវិទ្យាល័យភូមិន្ទកសិកម្ម
**Royal University of Agriculture**
## មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាព និង អាហារូបត្ថម្ភ
**Center of Excellence on Sustainable Agricultural Intensification and Nutrition**

# ឱកាសទទួលការគាំទ្រលើការស្រាវជ្រាវសារណាបទ សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ
## UNDERGRADUATE THESIS RESEARCH SUPPORT OPPORTUNITY
**(Only Students from Royal University of Agriculture)**

មជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ (CE SAIN) បានបង្កើតឡើងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID)។ មជ្ឈមណ្ឌលឧត្តមភាពបានចាប់ផ្តើមដំណើរជាផ្លូវការនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦។ ដោយមានតួនាទីជាអ្នកសម្របសម្រួលគម្រោងដែលកំពុងអនុវត្តដោយកម្មវិធីមន្ទីរពិសោធន៍នវានុវត្តន៍ (Feed the Future Innovation Labs) និងធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធិភាពនៃការអនុវត្តនិងចែករំលែកចំណេះដឹងស្តីពី ប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ(SAIN) តាមរយៈការដាក់បញ្ចូលបច្ចេកវិទ្យា ការស្រាវជ្រាវកសិកម្ម និងការផ្សព្វផ្សាយគំរូប្រព័ន្ធបច្ចេកវិទ្យាកសិកម្មថ្មីៗដល់កសិករ និងអ្នកពាក់ព័ន្ធផ្សេងៗ។ មជ្ឈមណ្ឌលឧត្តមភាព មានគោលដៅសំខាន់ៗ ៣៖

១.សម្របសម្រួល និងបង្កើនអនុភាពសកម្មភាពអនុវត្តគម្រោងរបស់កម្មវិធីមន្ទីរពិសោធន៍នវានុវត្តន៍និងសកម្មភាពផ្សេងៗដែលទាក់ទងនឹងប្រពលវប្បកម្មកសិកម្មនិរន្តភាពនិងអាហារូបត្ថម្ភ។

២.កសាង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាប័ននៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

៣.បង្កើតឧទ្យានបច្ចេកវិទ្យាកសិកម្មដើម្បីដាក់បង្ហាញបច្ចេកវិទ្យា និងយុទ្ធសាស្ត្រដែលមានសក្តានុពលខ្ពស់ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តប្រពលវប្បកម្មប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព។

មជ្ឈមណ្ឌលឧត្តមភាពបានបង្កើតឧទ្យានបច្ចេកវិទ្យាកសិកម្មចំនួន០៥កន្លែងផ្សេងគ្នា ដើម្បីជាមជ្ឈមណ្ឌលសម្រាប់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ សិស្ស និស្សិត ក្រុមហ៊ុនឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗ ធ្វើការស្រាវជ្រាវ ផ្តល់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាផ្សេងៗ រៀបចំទិវាស្រែ ឬបន្លែបង្ហាញ និងអនុវត្តនូវនវានុវត្តន៍បច្ចេកវិទ្យាកសិកម្មថ្មីៗដើម្បីជម្រុញលើកទឹកចិត្តដល់កសិករ ក្នុងការជ្រើសរើសបច្ចេកវិទ្យាដែលសមស្របក្នុងការបង្កើនផលិតភាព និងប្រាក់ចំណូលពីវិស័យកសិកម្ម។

ដើម្បីចូលរួមជំរុញការស្រាវជ្រាវ និងបង្កើនសមត្ថភាពដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម មជ្ឈមណ្ឌលឧត្តមភាពនឹងគាំទ្រ **និស្សិត** ចំនួន **១០ រូប** ធ្វើការស្រាវជ្រាវសារណាបទនៅតាមឧទ្យានបច្ចេកវិទ្យាកសិកម្ម ដែលមានទីតាំងនៅ(១) សាកលវិទ្យាល័យភូមិន្ទកសិកម្ម រាជធានីភ្នំពេញ (២) ស្ថានីយបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម (៣) វិទ្យាល័យរស្មីសោភ័ណ ស្រុកស្ទោង ខេត្តកំពង់ធំ (៤) ស្ថានីយស្រាវជ្រាវកសិកម្មទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប និង(៥) កសិដ្ឋានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃសាកលវិទ្យាល័យបាត់ដំបង ខេត្តបាត់ដំបង ឬនៅតាមទីតាំងនានាតាមការឯកភាពគ្នារវាងមជ្ឈមណ្ឌលឧត្តមភាព និង និស្សិតដោយផ្ទាល់។

Address: Room A0.3, Samdach Techo Hun Sen Building, Royal University of Agriculture,
Dangkor District, Phnom Penh 12401, P.O. Box 2696 | Tel: (855)23 6365 226 | E-mail: cesain@rua.edu.kh

## លក្ខខណ្ឌជ្រើសរើស

- និស្សិតទាំងពីរភេទ ដែលកំពុងសិក្សាឆ្នាំទី៤ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។
- និស្សិតទាំងពីរភេទ ត្រូវមានការតាំងចិត្តខ្ពស់ និងមានឆន្ទះក្នុងការរៀនសូត្រដើម្បីអភិវឌ្ឍខ្លួនឯង។
- និស្សិតទាំងពីរភេទ ត្រូវមានកម្រិតភាសាអង់គ្លេសសមរម្យ (អាចនិយាយ និងសរសេរបានខ្លះៗ)។

## រយៈពេលនៃការស្រាវជ្រាវ

- រយៈពេល **០៤ ខែ ទៅ ៦ខែ**

## ការគាំទ្រ

- មជ្ឈមណ្ឌលឧត្តមភាព នឹងផ្តល់ការគាំទ្រជាថវិកាចំណាយក្នុងស្រាវជ្រាវដែលបានស្នើរសុំ។ ថវិកាដែលនឹងផ្តល់ជូននេះគឺមិនអោយលើសពី **១០០០ដុល្លារអាមេរិក** សម្រាប់គម្រោងស្រាវជ្រាវនីមួយៗ ។
- អ្នកគ្រប់គ្រងឧទ្យានបច្ចេកវិទ្យាកសិកម្ម នឹងផ្តល់ការគាំទ្រ ដល់និស្សិតស្រាវជ្រាវកំឡុងពេលស្រាវជ្រាវ ក្នុងករណីគម្រោងនេះ ត្រូវបានស្រាវជ្រាវក្នុងឧទ្យានដោយផ្ទាល់។

## ការដាក់ពាក្យ

អ្នកដាក់ពាក្យស្នើសុំការគាំទ្រត្រូវភ្ជាប់មកជាមួយនូវៈ

- ពាក្យស្នើសុំ(Application Form)ចំនួន ០១ច្បាប់ (ទម្រង់ស្នើសុំផ្តល់ដោយមជ្ឈមណ្ឌលឧត្តមភាព)
- ផែនការសិក្សាស្រាវជ្រាវ(ទម្រង់ផែនការផ្តល់ដោយមជ្ឈមណ្ឌលឧត្តមភាព)
- ប្រវត្តិរូបសង្ខេបចំនួន០១ច្បាប់ដោយមានភ្ជាប់នូវឈ្មោះអ្នកដឹងឮយ៉ាងតិច ២ រូប
- លិខិតបង្ហាញចំណាប់អារម្មណ៍នៃការស្រាវជ្រាវ (Motivation Letter) ចំនួន០១ច្បាប់ ជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយបញ្ជាក់ទីតាំងដែលនឹងធ្វើការស្រាវជ្រាវច្បាស់លាស់។
- បំពេញទម្រង់សំនួរអំពីប្រភពព័ត៌មានដែលផ្តល់ដោយមជ្ឈមណ្ឌលឧត្តមភាព
- ផែនការប្រើប្រាស់ថវិការ (ទម្រង់ផែនការផ្តល់ដោយមជ្ឈមណ្ឌលឧត្តមភាព)

កាលបរិច្ឆេទទទួលពាក្យគឺចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ **ថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១៨** វេលាម៉ោង **០៤:៣០នាទីរសៀល**។ ដើម្បីទទួលបាននូវឯកសារពាក់ព័ន្ធនិស្សិតទាំងពីរភេទអាចទំនាក់ទំនងមកកាន់ការិយាល័យរបស់មជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ (CE SAIN) ដែលមានអាស័យដ្ឋាននៅបន្ទប់A0.៣ អាគារសម្តេចតេជោ ហ៊ុន សែន សាកលវិទ្យាល័យភូមិន្ទកសិកម្ម ឬ ទូរស័ព្ទលេខ **០២៣ ៦៣៦៥ ២២៦** ឬ អ៊ីម៉ែល cesain@rua.edu.kh។

សូមអរគុណ!